THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Tony B. Watlington Sr., Ed.D.**
Superintendent

ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

កាលពីសប្តាហ៍មុន ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា បានទទួលដំណឹងដ៏គួរឱ្យរំភើប។ កាលពីថ្ងៃពុធបាន ឃើញការចេញផ្សាយ ប័ណ្ណពិន្ទុនៃការអប់រំដែលត្រឡប់មកសភាពដើមវិញ Education Recovery Scorecard – របាយការណ៍ដែលចេញផ្សាយដោយ មជ្ឈមណ្ឌលស្រាវជ្រាវគោលការណ៍អប់រំ (Center for Education Policy Research) របស់សាកលវិទ្យាល័យ Harvard និង ផែនការនៃឱកាសសិក្សា (Educational Opportunity Project) នៅសាកលវិទ្យាល័យ Stanford ។ របាយការណ៍នេះបានស្រាវជ្រាវពីផលប៉ះពាល់នៃជំងឺរាតត្បាតមក លើការសិក្សារបស់សិស្ស និងអត្រាពិន្ទុនៃការអប់រំដែលត្រឡប់មកសភាពដើមវិញនៅតាមក្រសួងអប់រំក្នុងរដ្ឋ ចំនួន 30 ដែលតំណាងឱ្យប្រហែល 60% នៃចំនួនក្មេងក្នុងប្រទេសដែលមានអាយុត្រូវចូលរៀន។

យោងតាមការស្រាវជ្រាវនេះ **ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) បានត្រឡប់មកសភាពដើមវិញលឿន ជាងក្រសួងអប់រំផ្សេងៗទៀតក្នុងទីក្រុងធំៗទូទាំងប្រទេស និងក្រសួងអប់រំដែលស្រដៀងៗគ្នាក្នុងរដ្ឋផិនស៊ីលវេន ញ៉ា ក្នុងការត្រឡប់មកសភាពដើមវិញ ក្រោយពីពេលមានជំងឺរាតត្បាត។** ក្នុងផ្នែកគណិតវិទ្យា សិស្សនៅទីក្រុង ហ្វីឡាដែលហ្វ្យ៉ា បានត្រឡប់មកសភាពដើមវិញនូវកម្រិតសិក្សាជិតពាក់កណ្តាលនៃកម្រិតថ្នាក់ ក្នុងអំឡុងឆ្នាំ សិក្សា 2022-2023។ ក្នុងផ្នែកអាន សិស្សក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា បានកើនឡើងតិចជាងក្នុងរយៈពេលដូច គ្នា។ នេះជារបៀបដែល ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) ប្រៀបធៀប៖

- ប្រៀបធៀបនឹងក្រសួងអប់រំក្នុងទីក្រុងធំៗផ្សេងទៀតទូទាំងប្រទេស៖
    - ក្នុងផ្នែកគណិតវិទ្យា ប្រៀបធៀបនឹងក្រសួងអប់រំក្នុងទីក្រុងធំបំផុត និងក្រីក្របំផុតដែលធ្វើតេស្ត ក្នុង ការវាយតម្លៃការរីកចម្រើននៃការអប់រំក្នុងប្រទេស National Assessment of Educational Progress (NAEP) ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) បានកើនឡើងលឿនបំផុតក្នុង ការខិតជិតដល់កម្រិតជោគជ័យក្នុងផ្នែកគណិតវិទ្យា ជិតស្មើនឹងមុនពេលមានជំងឺរាតត្បាត។ ក្រសួងអប់រំនៃទីក្រុង Los Angeles (Los Angeles Unified School District) គឺជាក្រសួង អប់រំបន្ទាប់ដែលធ្វើបានស្ទើរតែដូចពីមុន។
    - ក្នុងផ្នែកអាន ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) បានលើសកម្រិតនៃការអានមុន ពេលមានជំងឺរាតត្បាត ហើយបានបង្ហាញពីការរីកចម្រើនច្រើនជាងក្រសួងអប់រំក្នុងទីក្រុងធំៗ ផ្សេងទៀតដែលចូលរួម តាំងពីឆ្នាំ 2019 ដល់ឆ្នាំ 2023 ហើយមានតែសាលារដ្ឋក្នុងទីក្រុង Chicago ប៉ុណ្ណោះដែលបង្ហាញការរីកចម្រើនដែលកាន់តែច្រើនឡើង។
- ប្រៀបធៀបនឹងក្រសួងអប់រំដែលស្រដៀងៗគ្នាក្នុងរដ្ឋផិនស៊ីលវេនញ៉ា៖

- ក្នុងផ្នែកគណិតវិទ្យា ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) កាន់តែខិតជិតដល់កម្រិតជោគជ័យមុនពេលមានជំងឺរាតត្បាត បើប្រៀបធៀបទៅនឹងរដ្ឋ និងក្រសួងអប់រំដែលស្រដៀងៗគ្នានៅក្នុងរដ្ឋ PA សាលារដ្ឋនៃទីក្រុង Pittsburgh ក្រសួងអប់រំនៃទីក្រុង Bethlehem សាលារដ្ឋនៃទីក្រុង Erie ក្រសួងអប់រំនៃទីក្រុង Scranton ក្រសួងអប់រំនៃទីក្រុង Wilkes-Barre (Pittsburgh Public Schools, Bethlehem Area School District, Erie Public Schools, Scranton School District, Wilkes-Barre Area School District)។
- ក្នុងផ្នែកអាន ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) បានលើសកម្រិតមុនពេលមានជម្ងឺរាតត្បាត បើធៀបទៅនឹងរដ្ឋ និងក្រសួងអប់រំដែលស្រដៀងៗគ្នា សាលារដ្ឋនៃទីក្រុង Pittsburgh ក្រសួងអប់រំនៃទីក្រុង Bethlehem សាលារដ្ឋនៃទីក្រុង Erie ក្រសួងអប់រំនៃទីក្រុង Scranton ក្រសួងអប់រំនៃទីក្រុង Wilkes-Barre (Pittsburgh Public Schools, Bethlehem Area School District, Erie Public Schools, Scranton School District, Wilkes-Barre Area School District) ដែលនៅតែមិនទាន់ត្រឡប់មកសភាពដើមវិញ។

លើសពីនេះ កាលពីសប្តាហ៍មុន ខ្ញុំមានកិត្តិយសក្នុងការថ្លែងសុន្ទរកថាស្តីពីការអប់រំជាធារណៈទៅកាន់រដ្ឋសម្រាប់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា លើកដំបូង។ ព្រឹត្តិការណ៍នេះបានផ្តល់នូវឱកាសដ៏មានតម្លៃសម្រាប់ក្រសួងអប់រំ និងក្រុមប្រឹក្សាអប់រំ ក្នុងការរួបរួមជាមួយទីក្រុងហ្វីឡាដែលហ្វ្យ៉ា ហើយចែករំលែកជាសាធារណៈនូវការរីកចម្រើនដែលយើងមាន យុទ្ធសាស្ត្ររបស់យើងសម្រាប់ការពន្លឿនជោគជ័យនៃការអប់រំបន្ថែមទៀត និងការអំពាវនាវឱ្យចាត់វិធានការ ដើម្បីបន្តការវិនិយោគទៅលើក្មេងនៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា។ ប្រសិនបើលោកអ្នកមិនបានចូលរួមក្នុងព្រឹត្តិការណ៍នេះ លោកអ្នកអាចមើលការថតចម្លង នៅទីនេះ។

ទិន្នន័យពី ប័ណ្ណពិន្ទុនៃការអប់រំដែលត្រឡប់មកសភាពដើមវិញ បញ្ជាក់ថា តាមការរួបរួមគ្នា យើងកំពុង *ពន្លឿនហ្វីល្លី Accelerating Philly!* ទោះបីជាយ៉ាងណាក៏ដោយ នេះជាពេលដែលយើងអបអរសាទរការរីកចម្រើននេះ ក្នុងនាមជាសហគមន៍ យើងនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ។ យើងនឹងបន្តសម្របធនធានរបស់យើង ដើម្បីបង្កើនលទ្ធផលរបស់សិស្ស និងក្លាយជាក្រសួងអប់រំក្នុងទីក្រុងធំដែលមានការរីកចម្រើនលឿនបំផុតនៅក្នុងប្រទេស។ ខ្ញុំសុំឱ្យលោកអ្នកបន្តការគាំទ្រ និងជាដៃគូ នៅពេលដែលយើងបន្តកិច្ចការដើម្បីរៀបចំសិស្សគ្រប់រូបឱ្យស្រមៃ និងសម្រេចនូវអនាគតដែលពួកគេចង់បាន។

ក្នុងភាពជាដៃគូ

*Tony*

Tony B. Watlington Sr., Ed.D.
អគ្គនាយកនៃក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា